ហេតុនេះហើយ បានជាក្រោយពីមានការប្រជុំពិគ្រោះយោបល់គ្នាដោយសម្ងាត់មក យើងបានសម្រេចថា ត្រូវតែស្វែងរកចិញ្ចឹមអាវុធ ឲ្យបានយ៉ាងតិច ១០ ដើមព្រួយ ដើម្បីសម្រេចគោលដៅរបស់យើង ឲ្យទាន់ពេលវេលា ពីព្រោះស្រែដែលទុំក្រហមសឹងពេញវាល យើងច្រូតមិនទាន់បានពាក់កណ្ដាលនៅឡើយនេះម៉្យាង ម៉្យាងទៀតយើងត្រូវគិតដល់រដូវស្រែខាងមុខ និងការរៀបចំសង់លំនៅដ្ឋាន និងភូមិដែលត្រូវនេះ ឬត្រូវបំផ្លាញឡើងវិញឲ្យបានមុនរដូវវស្សាជាចាំបាច់ ។

ដោយភារៈកិច្ចរកកាំភ្លើងនេះ ត្រូវធ្លាក់មកលើចីដោយផាត់ យើងក៏បានចេញដំណើរ រាំងថ្ងៃ ១២ មករា១៩៤៦ ឆ្ពោះទៅទីរួមខេត្តឃ្លាំង ជាមួយយុវជន ៦ នាក់ ក្នុងចំណោមនោះ មានលោក ឡាំ ប្រែក ជាអតីតពលបាលទោ ហៅចីដោយ ប្រែក ទៅជាមួយដែរ ។

តាមផ្លូវពីព្រែកគយ ទៅដល់ភូមិចាក់ខ្ចិង ចម្ងាយប្រហែល ១៥ គ.ម ពុំមានអ្វីនាំឲ្យបារម្ភទេ ប៉ុន្តែចាប់តាំងពីចាក់ខ្ចិងទៅ ជាតំបន់មានសុទ្ធតែពលរដ្ឋយួនទៅ ដូចជាទីប្រជុំជនបាយនៅ និងភូមិជាច្រើនពីបាយនៅ ទៅទីរួមខេត្តឃ្លាំងជាដើម ។ ដូចនេះយើងត្រូវផ្សងព្រេងដោយកាត់តាមវាលស្រែ សសៀរតាមជាយភូមិយួនតូច ៗ ដែល

មានចាប់ពីត្រើយព្រែកម្នាងគ្នោះទៅរកភូមិខ្មែរ យួនមួយក្បែរ ទីរួមខេត្តហៅថាភូមិ ១យ៉ើ «ប្រែមកថាភូមិឃ្លាំងប្រេង» ចម្ងាយពីភូមិចាក់ទ្វិងទៅប្រហែល ៣ គ.ម ។ ដើម្បី ជៀសវាងគ្រោះថ្នាក់ ដែលមានឡើង ក្នុងពេលឆ្លងកាត់ភូមិ សត្រូវ យើងត្រូវពួនសំរាកដោយជ្រកតាមព្រៃកំបុត ។ ពេលដែលយើងចូលទៅដល់កន្លែងលាក់ខ្លួន ក្បែរមាត់ព្រែក សាកសពដែលអណ្តែតសន្ធឹម ៗ តាមជំនោរទឹកក្បែរយើង បាននាំឲ្យយើងកើតក្តីសង្វេគនឹកគិតដល់បងប្អូនយើងឯព្រែក គយ នឹកដល់គ្រួសារយើង ដែលទើបទទួលការឈឺចាប់ ព្រោះមានកូនប្រុសមួយស្លាប់ ដោយការនឿយហត់ និងតក់ស្លុត នៅពេលម្តាយនាំរត់កាត់វាលចម្ងាយ ៧ គ.ម និងនឹក ដល់គ្រោះភ័យដែលរង់ចាំយើងថ្ងៃស្អែក ។ ពេលដែល យើងត្រូវឆ្លងកាត់ភូមិយួន តើយើងត្រូវអណ្តែតទឹក ដូចគ្នា នេះដែរឬ ? ប៉ុន្តែក្តីកង្វល់ទាំងនេះ វានៅតែត្រឹមក្តីកង្វល់ វាគ្រាន់តែធ្វើឲ្យយើងដេកមិនលក់ ពីព្រោះវាសនាបងប្អូន យើងរាប់ម៉ឺននាក់បានដាស់សតិយើង មិនឲ្យមានក្តីរារែកអ្វី ទៀតជាដាច់ខាត ។

នៅម៉ោង ៤ ទៀបភ្លឺ យើងរៀបចំចេញដំណើរ បំបែក គ្នាយើងជាក្រុមតូច ៗ ៣ ក្រុម ហើយយើងសន្យាទៅជួប គ្នានៅ ១យ៉ើ ចាប់ពីម៉ោង ១០ ព្រឹកទៅទល់គ្នានឹងយប់ ។

ប្រហែលម៉ោង ៥ ស្រាងៗក្រោយពីទួលព្រែកក្រូច ហើយក៏បំបែកគ្នាផ្សងព្រេងតែរៀងខ្លួន ៗ រហូតម៉ោង ៥ នៅកម្ពុជាក្រោមហៅ ក្រហមឯកើត «ព្រះអាទិត្យចាប់រះ» ស្នូរកាំភ្លើងបានឮឡើងប្រហែលជាមួយគីឡូម៉ែត្រពីយើងក្រោយបន្តិចមក ឮស្នូរក្ដែព្រុសព្រូហ៊ឺងអ៊ឹងកងនៅកន្លែងដែលយើងឥតមានអ្វីឆ្ងល់ទៀតទេ បើ ប្អូនរួមអាវុធក្រុមណាមួយត្រូវខ្មាំងប្រហារហើយ ៗ លុះយើងទៅដល់ ទយ៉ូវ ការស្មានរបស់យើងក៏ទៅជាការពិត ប្អូនឆ្លួន និង ប្អូនពី ត្រូវយួនចាប់សម្លាប់ស្រេច ៗ.

ពេលចូលទៅដល់ទីក្រុងនៅពេលយប់ មិត្តភក្តិយើងឈ្មោះ ចេវ សាញ់ ដែលធ្លាប់បំរើកងទ័ពជួចគ្នាកាលជំនាន់នោះ បានជួយទាក់ទងជាមួយនាយទាហានជប៉ុនដែលរង់ចាំទ័ពសម្ព័ន្ធមិត្តមកដកអាវុធ ហើយទិញអាវុធ ១៦ ដើមតម្លៃតែពីរម៉ឺនពៀស( Piastres )ញ៉ូយប៉ុណ្ណោះ ៗ

ចាប់តាំងពីយើងមានពិសភ្វាម យើងរីករាយណាស់ ៗ រីករាយទៅទៀតត្រង់មិត្តភក្តិយើង គេជួយរើសអ្នកស្ម័គ្រចិត្តដែលគេទុកចិត្តទៅជួយយើងបាន ៨ នាក់ទៀត គ្រប់តាមចំនួនអាវុធ ១៦ ដើម ៗ យើងសូមបើកវង់ក្រចកបញ្ជាក់ថាអាវុធដែលទិញបាន យើងឥតហ៊ានបញ្ចេញឲ្យអ្នកផងឃើញទេ ពីព្រោះវាអាចទៅជានាំឲ្យគ្រោះថ្នាក់ដល់យើងផង

ដល់ខាងទាហានជប៉ុនដែលអាណិតយើងនោះផង ។ នៅតាមផ្លូវវិលទៅព្រែក ធំ ទៀតសោត យើងចេញដំណើរនៅពេលក្នុងដេកលក់ យើងស្លូតដំណើរតែមួយយប់ដល់ភូមិ ដៃនង់ ចម្ងាយប្រហែល ២០ គ.ម ពីឃ្លាំងដោយដើរកាត់តាមវាលស្រែឆ្ងាយពីភូមិអ្នកស្រុក ។

ពេលចូលដល់ភូមិ ដៃនង់ ដែលជាភូមិខ្មែរមួយស្ងាត់ស្ងៀម និងក្រោយពីបានលាក់អាវុធក្នុងព្រៃចាកមក យើងបង្ហាញខ្លួនឲ្យអ្នកស្រុកឃើញ ដើម្បីសាកសួរពីស្ថានការណ៍ទាំងមាត់សមុទ្រ ។ យើងស្នាក់នៅក្នុងភូមិនេះចំនួនមួយសប្តាហ៍ ឥតឲ្យមានលេចឮពីរឿងយើងមានអាវុធទេ ។ បានជាយើងត្រូវប្រើកលល្បិចដូចនេះ គឺព្រោះយើងចង់ឲ្យសត្រូវដែលតែងតែមកក្តោបផុតផ្ទះ កាប់សម្លាប់ បង ប្អូនយើងនោះ ចូលស៊ិតយើងម្តងវិញ ។

នៅថ្ងៃ ១៨ មករា ១៩៤៦ អ្នកនាំសារមកពីសេនាធិការរបស់យើង បានមកឲ្យយើងដឹងថា មេទ័ពសួននៅកោះកុងដឹង បានឲ្យយើងដឹងថា យើងត្រូវឈប់ឈ្លោះគ្នា ហើយដើម្បីបង្ហាញការស្មោះត្រង់របស់យើង យើងត្រូវប្រគល់ទង់ជាតិរូបប្រាសាទទៅឲ្យគេ បើពុំនោះទេ គេនឹងទៅហៅទ័ពបន្ថែមពីខេត្តព្រះត្រពាំង មកកំទេចយើងឲ្យអស់ ។

ចំពោះការគំរាមកំហែងបោកប្រាសយ៉ាងនេះ យើងក៏

បានតបទៅគេវិញថា ទង់ជាតិរបស់យើងជ្រុះបាត់នៅពេលប្រយុទ្ធគ្នា នៅបឹងព្រលិតនោះទៅហើយ ។ អង្វរគេឱ្យគេអាណិត ។

ដោយជួបប្រទះនិងស្ថានការណ៍ថ្មីបែបនេះ យើងត្រូវមានការប្រុងប្រយ័ត្នលើសដើម ដោយហេតុនេះបានជាយើងចាកចេញពីផែនដីដោយទូក ធ្វើដំណើរទៅតំបន់មាត់សមុទ្រដែលជាកន្លែងយួនធ្លាប់ចូលមកធ្វើបាបយើង ។

នៅតាមផ្លូវ លុះចូលទៅដល់ផ្ទះលោកតា ថាច់ ហ៊ុម នៅក្បែរសេនាធិការដ្ឋានយើង ក៏ស្រាប់តែមានអ្នកនាំសារបំផាយសេះមកឱ្យដំណឹងយើងថា អ្នកយាមនៅតាមមាត់សមុទ្រកូនក្អែក ឃើញពលនាវាទូកក្ដោងជាច្រើននៅពេលព្រលប់ នៅចុងកោះពាក់កណ្ដាល ត្រើយនៃសមុទ្រម្ខាងនៃផ្សារកូនក្អែក«ជាកោះដែលល្បប់ទន្លេមេគង្គបង្កបង្កើតឡើង» ។ ប្រហែលពីរម៉ោងក្រោយមក គឺវេលាម៉ោង ៦ ព្រឹក អ្នកនាំសារម្នាក់ទៀត បានមកដល់ប្រាប់យើងថា ទ័ពយួនចំនួន ២៧ ទូកសមុទ្រ បានចូលមកតាមទ្វារទំនប់ព្រែក កូនក្អែក ហើយចាប់បាញ់អ្នកស្រុក និង ដុតបំផ្លាញផ្ទះជាច្រើនខ្នង ។ អ្នកនាំសារបានបញ្ជាក់ទៀតថា បង ប្អូនយើងដែលរត់មកពីភូមិខ្ទួនតាធំមកជួយ ចូលមិនចុះ ដោយយួនបាញ់ខ្លាំងពេកប៉ុន្តែបង ប្អូនទាំងនោះមិនព្រមត្រឡប់ទៅវិញទេ រង់ចាំ

យើងលើកគ្នាទៅជួយ ៗ បង ប្អូន យើងខាង ភូមក្រែក អ្នកតងត្រោះ ដែលបានជម្លៀស ស្រី-ចាស់-ក្មេង ទៅភូមិ ដើមពោធិ៍និងទៅភូមិ ព្រែកគយ ក៏បានប្រជាប់ការបិត ពួចៅ ចាំយើងផង គ្រង់នេះសូមបញ្ជាក់ថា បងប្អូនយើងឥតមាន ដំណឹងថាយើងមានអាវុធ ១២ ដើមនេះនៅឡើយទេ ៗ

ក្រោយពីយើងយកអាវុធពីទូកមកបង្ហាញគាត់លោកតា ថាច់ ហ៊ុម អាយុជិត ៦០ ឆ្នាំទៅហើយ តែដោយអំណាច សេចក្ដីក្រោធរបស់គាត់ ៗ ស្ម័គ្រចិត្តទៅច្បាំងជាមួយ យើង ៗ សូមជំរាបថា លោក ថាច់ ហ៊ុម ជាអាចារ្យវត្ត ពោធិព្រឹក្សជង ជាគ្រូភ្លេងពិណពាទ្យផង ជាគ្រូប្រក់ព្រំទ័ព យើងផង និងជាទីប្រឹក្សារបស់សេនាធិការយើងផង ៗ

ដើម្បីធ្វើឲ្យខ្មាំងបណ្ដោយឲ្យយើងចូលកិត យើងក៏ សម្រេចចិត្តរកកាំភ្លើងនិងកន្ទួលខ្វះ ខ្វះទៀតចងផ្កាបមស៊ីរ្យ ធម្មតា ៗ សូម្បីបង ប្អូនយើងក៏ប្រឡំដែរ ៗ យើងទៅ ដល់ទីលានប្រយុទ្ធវេលាម៉ោង ៨ ព្រឹក ៗ នៅតាមផ្លូវបង ប្អូនយើង ដែលនៅចាំយើង រាប់ច្រើនរយនាក់បាន «ហៅ» យើងទៅ គេហៅដោយសារគេទុកចិត្តទៅលើកាំភ្លើងប្រ មាញ់ពីរដើមដែលគេធ្លាប់ឃើញគ្រប់សមរភូមិមកហើយ ៗ បង ប្អូនយើងខ្លះដែលស្គាល់ទ្រព្យរបស់គេក ក៏ស្ងីនៅតែ គេចចុះគេចឡើង តាមផ្លូវដើមផ្ទុងក្នុងភូមិ ដើម្បីបណ្ដោះសត្រូ

វាហនៈនិងរបស់ដែលនៅសល់ខ្លះ ៗ ពេលនោះយួនឥតរវល់នឹងយើងទេ គេគិតតែពីសាងវិនាសកម្ម ៗ

នៅប្រហែល ៣០០ ម ពីភូមិ យើងចាប់ស្រាយរមូរកន្ទេល ស្រាយបំពង់ឫស្សី អ្នកស្រុកដែលដើរពីក្រោយគ្រាន់តែឃើញកាំភ្លើង ១៦ ដើមថ្មីស្រឡាងភ្លាម ស្រែកហ៊ោសឹងរបើកមេឃ លុះដើរបានប្រហែល ១០០ ម ទៅមុខទៀត ក៏ចំពួកយួនរត់សំរុកមករកយើង ស្រែកបណ្ដើររត់ចូលបណ្ដើរ ជាមួយកាំភ្លើងពីរដើម ដែលយើងឃើញច្បាស់ កាំភ្លើងឯទៀត ប្រហែលជាជាប់នៅការពារពួកដុតផ្ទះ ៗ គ្រាន់តែឮស្នូរវា យើងដឹងស្រេចថា ជាកាំភ្លើងប្រមាញ់ ៗ

លោកតា ហ៊ុម ដែលគាត់ទើបតែស្គាល់កាំភ្លើងជាលើកដំបូង ហើយទើបរៀនបាញ់ពេលមុនចេញពីផ្ទះសោះនោះ បានធ្វើឱ្យលោះដៃទៅត្រូវមេឃអស់មួយគ្រាប់ ៗ យួនឮដូចនេះ រឹតតែស្រែកៈ ទៀង- ទៀង- ទៀងគិយ . « ចូល- ចូល- ចូលឱ្យកិត » ខ្លាំងឡើង ៗ ដោយស្រែកប្រាប់គ្នាថាៈ «ស៊ុងយ៉ា» «កាំភ្លើងធ្វើអាយុ» លុះឃើញមួយគ្រាប់ទៀតល្បើកក្តីស្រែ ចំពួកយៀកមិញក៏ឈប់ដំណើរភ្លាម ប៉ុន្តែមួយប៉ព្រិចភ្នែកក្រោយមក ក៏របាលចូលមករកចំពួកយើងទាំងគំរោល ៗ ការប្រឡូកគ្នា ក៏បាន

ចាប់ផ្ដើមឡើងប្រៀបបានដូចរន្ទះទាំង ៧ ។

ប្រហែលជាកន្លះម៉ោងក្រោយមក ទ័ពខ្មែរ ដែលពោរពេញទៅដោយកំហឹងស្រាប់ ក៏បានវាយសន្ធាប់ទ័ពយួនឲ្យដោះដៃពីវាលស្រែ ថយចូលទៅរកភូមិដែលវាទើបបានដុតបំផ្លាញនោះវិញ ។ លុះប្រកាប់ប្រចាក់គ្នានៅជុំវិញអគ្គីភ័យនោះប្រហែល ១០ នាទីមក ទ័ពយួនក៏ត្រូវបង្ខំចិត្តលោតចុះក្នុងព្រែកកូនក្អែក ក្នុងគោលបំណងឆ្លងទៅត្រើយម្ខាងទៀត ប៉ុន្តែក្នុងចំណោមមនុស្សប្រហែល ២០០ ញុយនាក់ដែលបានលោតចុះក្នុងព្រែកនោះ មានមួយភាគត្រូវធ្លាក់ក្នុងអន្ទាក់របស់បង ប្អូន យើងដែលមកពីទិចគាង ។ ម្យ៉ាងទៀតទូកសមុទ្រចំនួន ២៧ គ្រឿង ដែលយួនយៀកមិញធ្វើដំណើរឆ្លងសមុទ្រ មកដុតបំផ្លាញផ្ទះ និងកាប់សម្លាប់ បងប្អូនខ្មែរយើង ដែលចងលាក់ក្នុងព្រែកក្បែរសមុទ្រ ក៏ត្រូវបង ប្អូនយើង មួយក្រុមទៀតមកពីបឹងត្រលិត បំផ្លាញខ្ទេចខ្ទីអស់ដែរ ។ យួនឯទៀត ដែលបាក់ទ័ពរត់ប្រសេចប្រសាចពីលានប្រយុទ្ធ បានរស់រានមានជីវិតខ្លះ ក៏ដោយសាររត់រត់ទៅពួនក្នុងព្រៃចាក នៅក្បែរមាត់សមុទ្រ ឬនៅតាមភូមិយួនដែលស្ថិតនៅឆ្ងាយពីសមរភូមិ ។

ក្រោយពីបានទទួលជោគជ័យ និងប្រមូលបានអាវុធ ១០ ដើមញុយ និង ព្រួញ- ស្នា- លំពែង- កាំបិតយួកិច

ប្រហែលចំណុះ មួយទូកមក និងក្រោយពីបានប្រគល់អ្នករបួសឱ្យក្រុមចិននៅក្នុងក្អែកជួយព្យាបាល និងសំដែងសមានទុក្ខចំពោះគ្រួសារអ្នកស្លាប់ ២០ បាយនាក់នោះមកយើងក៏បាននាំឱ្យក្រុមកាកបាទក្រហម ដែលកើតឡើងក្នុងជំនាន់យៀកមិញ ជួយប្រមូលសាកសពយួន យកទៅកប់ឱ្យបានត្រឹមត្រូវផង ។

មិនតែប៉ុណ្ណោះ យើងបានចែកគ្នាឱ្យចេញទៅ ល្បាតតាមមាត់សមុទ្រចំនួនច្រើនថ្ងៃ និងបានចាត់គ្នាយើងពីរក្រុមទៀត ឱ្យដើរល្បាតគ្រប់ទិសទី ដើម្បីទប់ទល់នឹងប្រតិកម្មផ្សេង ៗ ដែលអាចកើតមានឡើងពីខ្មាំងទៀត ។

* *

*

បន្ទាប់ពីការទប់ទល់ប្រកបដោយជោគជ័យនេះចំនួនប្រហែល ១៥ ថ្ងៃមក ក៏គ្មានឃើញហេតុភេទអ្វីជាដុំកំភួនកើតឡើងទៀតទេ រីឯការកាប់សម្លាប់គ្នានៅតាមភូមិនានា ក៏មានការថមថយច្រើន ។

ប៉ុន្តែវិនាសកម្ម បានផ្ទុះទៅបន្តបង្កើតនៅក្នុងខេត្តគលលាវឯណោះ ហេតុដូចនេះហើយ បានជាយើងត្រូវរំលែក

គ្នាទៅជួយ បង ប្អូនភូមិស្វាយ ហើយជំរុលទៅចាប់ដៃនឹង លោកគូ គិន ហៅចៅហ្វាយ គិន ដែលជាអ្នកដឹកនាំពល នាគស៊ីរបស់បង ប្អូនយើងនៅព្រៃវាយញារ ខេត្តពលសាវ ៗ ពេលត្រឡប់វិលវិញ យើងបានវាយរំដោះ បានអ្នកជាប់ឃុំ ចំនួន ៣៧ នាក់ ដែលសត្រូវទុកយកទៅឲ្យ « រាវបង្គង » នៅពេលចូលឆ្នាំចិន-យួនរួច ៗ រាវបង្គង ជាកាសិតយួន ចង្អុលការសម្លាប់មនុស្សដោយច្រមុះជីក ឬ កាប់បណ្ដាក់ ទឹក ។ ៗ